**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**

# សេចក្តីប្រកាសព័ត៌មាន

អនុវត្តតាមយុទ្ធសាស្ត្រកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលឱ្យក្រសួងរ៉ែ និងថាមពល ផ្អាកជាបណ្តោះអាសន្ន ការផ្តល់អាជ្ញាប័ណ្ណថ្មី និងធ្វើការពិនិត្យ និងវាយតម្លៃឡើងវិញនូវក្រុមហ៊ុនដែលមានអាជ្ញាបណ្ណស្រាប់ និងសកម្មភាពអនាធិបតេយ្យជីកយករ៉ែទាំងឡាយនៅទូទាំងប្រទេស ក្រសួងរ៉ែ និងថាមពល បានសម្រេចបង្កើតក្រុមការងារអធិការកិច្ចចំនួន ៣ ក្រុមដែលមួយក្រុមៗ ដឹកនាំដោយរដ្ឋលេខាធិការមួយរូប និងមន្ត្រីជំនាញមួយក្រុម៖

១. ក្រុមទី១ដឹកនាំដោយ ឯកឧត្តម ម៉េង សក្តិធារ៉ា រដ្ឋលេខាធិការ ទទួលបន្ទុកចុះត្រួតពិនិត្យនៅបណ្តាខេត្តនៃតំបន់ភាគឥសាន។
២. ក្រុមទី ២ ដឹកនាំដោយ ឯកឧត្តម ហូ វិចិត្រ រដ្ឋលេខាធិការ ទទួលបន្ទុកចុះត្រួតពិនិត្យនៅបណ្តាខេត្តនៃតំបន់ភាគពាយ័ព្យ។
៣. ក្រុមទី ៣ ដឹកនាំដោយ ឯកឧត្តម ឌិត ទីណា រដ្ឋលេខាធិការ ទទួលបន្ទុកចុះត្រួតពិនិត្យនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងបណ្តាខេត្តនៃតំបន់ភាគនិរតី។

ក្រុមការងារអធិការកិច្ចទាំងបីក្រុមដែលចុះធ្វើអធិការកិច្ចបានជួបប្រទះនឹងបញ្ហាដូចៗគ្នា ដែលត្រូវដោះស្រាយបន្ទាន់គឺការចេញអាជ្ញាបណ្ណខ្សាច់ឱ្យធ្វើអាជីវកម្មបានទាន់ពេលវេលា និងការដោះស្រាយភាពមិនប្រក្រតីនៃការធ្វើអាជីវកម្មរ៉ែផ្សេងៗទៀត ដោយអនាធិបតេយ្យ និងមិនត្រឹមត្រូវតាមកិច្ចព្រមព្រៀងរវាងក្រុមហ៊ុន និងក្រសួងរ៉ែ និងថាមពល។

ដើម្បីដោះស្រាយបញ្ហាបន្ទាន់នេះ រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចលេខ ២០ សសរ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកំណត់គោលការណ៍ធ្វើអាជីវកម្មខ្សាច់ដែលប្រគល់ភារកិច្ចឱ្យក្រសួងរ៉ែ និងថាមពល ជាអ្នកចេញអាជ្ញាបណ្ណ និងទទួលខុសត្រូវគ្រប់បែបយ៉ាងលើការធ្វើអាជីវកម្មខ្សាច់គ្រប់ប្រភេទ ថ្នាក់ដឹកនាំក្រសួងបានបើកកិច្ចប្រជុំនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ដើម្បីជជែកពិភាក្សាពីវិធានការ និងការកំណត់ធ្វើផែនការក្នុងការពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងអាជីវកម្មនេះ។

អង្គប្រជុំបានសម្រេច និងឯកភាពទៅលើសកម្មភាពនិងវិធានការមួយចំនួនជាបន្ទាន់ ដែលត្រូវដាក់ចេញដូចមានខាងក្រោម៖

១. បន្តពន្យារអាជ្ញាបណ្ណដែលមានស្រាប់នៅក្នុងតំបន់ដែលបានសិក្សារួចជាស្រេចទៅលើផលប៉ះពាល់សង្គម សេដ្ឋកិច្ច និងបរិស្ថាន។

២. ចំពោះអាជ្ញាបណ្ណថ្មីក្នុងតំបន់ថ្មីត្រូវតែមានការវាយតម្លៃ និងសិក្សាឱ្យបានច្បាស់លាស់ជាមុនសិនទៅលើផលប៉ះពាល់សង្គម សេដ្ឋកិច្ច និងបរិស្ថាន ពីក្រុមជំនាញបច្ចេកទេសដែលទទួលស្គាល់ដោយក្រសួងបរិស្ថាន និងក្រសួងរ៉ែនិងថាមពល។

៣. ប្រកាសអន្តរក្រសួង រវាងក្រសួងរ៉ែ និងថាមពល និងក្រសួងបរិស្ថាន នឹងត្រូវរៀបចំឡើងដើម្បីសហការវាយតម្លៃសិក្សាពីផលប៉ះពាល់បរិស្ថាន (Environmental Impact Assessment - EIA) និងផែនការកាត់បន្ថយការប៉ះពាល់បរិស្ថាន (Environmental Mitigation Plan-EMP)។

៤. យុទ្ធនាការ "ថ្នាំទន្លេ"៖ គឺជាការប្រមូលផ្តុំកងកម្លាំងទាំងអស់ដើម្បីការពារទន្លេ ប្រឆាំងទប់ស្កាត់នឹងការធ្វើអាជីវកម្មខ្សាច់ខុសច្បាប់។ កិច្ចប្រជុំមួយចំនួន នឹងត្រូវធ្វើជាបន្ទាន់ជាមួយអាជ្ញាធរមូលដ្ឋានដើម្បីកំណត់វិធានការ និងសកម្មភាពឱ្យបានច្បាស់លាស់ដើម្បីដោះស្រាយបញ្ហានេះ។

៥. បង្កើតឱ្យមានលេខទូរស័ព្ទ (Hotline) ដើម្បីទទួលបណ្តឹងទាក់ទងទៅនឹងការបូមខ្សាច់អនាធិបតេយ្យនៅតាមសមុទ្រ ដងទន្លេ និងស្ទឹង។

៦. រៀបចំ និងពិនិត្យឡើងវិញនូវរាល់លក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណ ដើម្បីពង្រឹងការអនុវត្តកាតព្វកិច្ចក្នុងការទទួលខុសត្រូវផ្នែកសង្គម ការត្រួតពិនិត្យ និងការអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

៧. ក្រសួងនឹងធ្វើលទ្ធកម្មជ្រើសរើសអ្នកជំនាញបច្ចេកទេសបរិស្ថាន ដើម្បីជួយធ្វើការសិក្សាតំបន់ដែលអាចធ្វើអាជីវកម្មខ្សាច់បានដោយមិនប៉ះពាល់ដល់ច្រាំងសមុទ្រ ទន្លេ និងស្ទឹង។

វិធានការទាំងអស់នេះ ជាកម្មវិធីអាទិភាពរបស់ក្រសួងរ៉ែ និងថាមពល នៅក្នុងការដោះស្រាយបញ្ហាអាជីវកម្មខ្សាច់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥